# សប្បុរសជនជួយគាំទ្រការបង្រៀនអក្សរសាស្ត្រខ្មែរនៅសុរិន្ទ

**រាជធានីភ្នំពេញ** ៖ ក្នុងដំណើរទស្សនកិច្ចផ្ទាល់ខ្លួនមួយមកកាន់ខេត្របាត់ដំបង និងរាជធានីភ្នំពេញ ដើម្បីផ្សព្វផ្សាយ និងស្វះស្វែងរកការគាំទ្រពីប្រជាពលរដ្ឋខ្មែរដែលស្រឡាញ់ការអភិរក្សអក្សរសាស្ត្រខ្មែរនៅខេត្រសុរិន្ទ ប្រទេសថៃ (ដែលខេត្រមួយនេះក្នុងចំណោមខេត្រជាច្រើនទៀតជាទឹកដីរបស់ខ្មែរកាលពីអតីតកាល) លោក ជ័យមង្គល បានជួបសំណេះសំណាលជាមួយបងប្អូនខ្មែរជាច្រើនក្រុម និងបានបង្ហាញអំពីកិច្ចការ និងគោលបំណងរបស់លោក។

ដោយឡែកក្នុងជំនួបជាមួយតំណាងសប្បុរសជនមួយក្រុម នៅរាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ នេះ លោក ជ័យមង្គល បានសម្តែងនូវទឹកចិត្តសប្បាយរីករាយដែលបានជួបសំណេះសំណាលជាមួយបងប្អូនខ្មែរ និងបានទទួលការគាំទ្រដោយទឹកចិត្ត ថវិកា និងសម្ភារ ក្នុងនាមជាខ្មែរដូចគ្នាទោះតិចក្តីច្រើនក្តី។

លោកបញ្ជាក់ថាមូលហេតុដែលជំរុញលោកឲ្យមានគំនិតបង្រៀនភាសាខ្មែរនេះ ដោយសារលោកមានទឹកចិត្តជាខ្មែរ ស្រឡាញ់អក្សរសាស្ត្រខ្មែរ។ លោកបន្ថែមថា តាមការស្រាវជ្រាវមួយបានប៉ាន់ប្រមាណថានៅសុរិន្ទ មានប្រជាពលរដ្ឋដើមកំណើតខ្មែរប្រមាណ ៦០% (ប្រហែលជាង ៧សែននាក់) ប៉ុន្តែក្នុងចំណោមនេះមានមនុស្សប្រមាណ ១% ប៉ុណ្ណោះដែលចេះអាន និងនិយាយខ្មែរ។ លោកបានសួរខ្លួនឯងថាមនុស្សគ្រប់គ្នាសុទ្ធតែមានដើមកំណើតជាខ្មែរ ហេតុអ្វីបានជាមិនមានសាលាភាសាខ្មែរ ហើយហេតុអ្វីបានជាមានមនុស្សតិចម្ល៉េះដែលនិយាយភាសាខ្មែរ។ ដូច្នេះលោកត្រូវទទួលយកកិច្ចការដ៏លំបាកមួយនេះ ក្នុងពេលដែលលោកមិនទាំងដឹងច្បាស់ថាត្រូវចាប់ផ្តើមពីត្រឹមណាឲ្យប្រាកដក៏ដោយ។ មានមនុស្សមួយចំនួននិយាយថាវាហួសពេល ឬមិនអាចទៅរួចទេក្នុងការធ្វើកិច្ចការនេះ ប៉ុន្តែលោកបញ្ជាក់ទៅវិញថាដោយសារតែគំនិតនេះហើយទើបខ្មែរមិនចេះភាសាខ្មែរខ្លួនឯង ហើយបើមិនអាចទៅរួចក៏លោកត្រូវតែធ្វើដែរ ដើម្បីបញ្ជាក់ថាលោកបានខំអស់ពីសមត្ថភាពលោកហើយ ប្រៀបដូចជាអ្នកប្រដាល់ដូច្នោះដែរ។ ទោះជាយ៉ាងណាក៏លោកនៅតែមានក្តីសង្ឃឹមជានិច្ច។

ឆ្លៀតឱកាសនោះផងដែរ លោកជ័យមង្គលសូមអំពាវនាវដល់សប្បុរសជនទាំងអស់ ជាពិសេសប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈ មេត្តាជួយគាំទ្រលោក ដើម្បីលោកអាចបន្តសាបព្រោះភាសាខ្មែរយើងនៅលើទឹកដីដែលសម្បូរដោយជនជាតិដើមខ្មែរ។ នេះមិនមែនជារឿងនយោបាយ ឬការបង្កើតក្រុមអ្វីមួយ ឬគាស់កកាយប្រវត្តិសាស្ត្រ ឬយើងចង់ប្រឆាំងប្រទេសណាមួយនោះទេ តែជាការជួយគ្នាក្នុងនាមជនដែលមានឈាមជ័រដូចគ្នា យ៉ាងហោចណាស់ក៏យើងអាចធ្វើទំនាក់ទំនងរវាងគ្នានិងគ្នាបានស្រួលដែរ។

ជាចុងក្រោយ លោកបានសំដែងនូវអំណរគុណចំពោះសមានចិត្តសប្បុរសជនដែលបានបរិច្ចាកប្រាក់កាស និងសម្ភារសិក្សាដ៏មានតម្លៃដែលផុសចេញពីទឹកចិត្តដ៏បរិសុទ្ធសម្រាប់លោក។

ចំណែកតំណាងសប្បុរសជនក៏បានសម្តែងនូវទឹកចិត្តរាប់អាន និងក្តីរីករាយចំពោះជំនួបនេះផងដែរ និងបានសន្យាបន្តស្វែងរកថវិកាតាមលទ្ធភាព ដើម្បីរួមចំណែកលើកតម្កើងអក្សរសាស្ត្រខ្មែរនៅលើដែនដីដែលសម្បូរដោយជនអម្បូរខ្មែរ។

តំណាងសប្បុរសជនខ្មែរបានប្រគល់ថវិកា និងសម្ភារមួយចំនួនដែលប្រមូលបាន សរុបចំនួន ២៥២ដុល្លាសហរដ្ឋអាមេរិក និងសៀវភៅអានចំនួន ២៩ក្បាល (សៀវភៅសន្ទនាអង់គ្លេស-ខ្មែរ-បារាំង ចំនួន ៥ក្បាល និងសៀវភៅអានសម្រាប់ក្មេងៗចំនួន ២២ក្បាល) និងខ្មៅដៃចំនួន ៣០ដើម។

សូមបញ្ជាក់ថា លោក ជ័យមង្គលគឺជាស្ថានិកនៃការបង្រៀនភាសាខ្មែរនៅសុរិន្ទ ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០៦មក ដែលរហូតមកដល់ពេលនេះ លោកបានបើកថ្នាក់បង្រៀនភាសាខ្មែរបានចំនួន ៦កន្លែង ដែលមានសិស្សសរុបចំនួន ១៨៥នាក់។ លោកបានកើតនៅស្រុកកោះខាន់ក្នុងខេត្តស្រីសាកេតដែលជាខេត្តមួយជាប់នឹងខេត្តសុរិន្ទដែរ។ លោកធំដឹងក្តីនៅក្នុងគ្រួសារដែលនិយាយភាសាខ្មែរ ប៉ុន្តែមានតែលោកមួយប៉ុណ្ណោះដែលរក្សាការនិយាយភាសាខ្មែររហូតមកដល់បច្ចុប្បន្ននេះ។ លោកធ្លាប់មកសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញកាលពីឆ្នាំ ១៩៩៦-១៩៩៧។

គួរបញ្ជាក់ផងដែរថា សុរិន្ទ និងសហាគមន៍ផ្នែកខាងជើងភ្នំដងរែក ត្រូវបានគេស្គាល់ថាសម្បូរដោយជនជាតិខ្មែរ និងជាអតីតដែនដីរបស់ខ្មែរ ដែលគេតែងហៅថា "ខ្មែរសុរិន្ទខ្នងភ្នំ"។ មានទីកន្លែង ឬភូមិស្រុកមួយចំនួននៅរក្សាឈ្មោះដើមជាខ្មែរដដែល គ្រាន់តែសរសេរជាភាសាថៃ ដូចជា ភូមិថ្ងៃត្រង់ ជាដើម។

## សប្បុរសជនឧបត្ថម្ភថវិកា និងសម្ភារជូនលោក ជ័យមង្គល

| No. | Name | Phone | $ | Riel | Materials |
|---|---|---|---|---|---|
| 1 | Mr. Ny KeoPonha | 016 543 755 | 20 | | |
| 2 | Mr. Keo Chamroeun | 012 867 438 | 20 | | |
| 3 | Mr. Thong Phirum | 012 672 498 | 20 | | |
| 4 | Mr. Phy Sophon | 012 933 539 | 20 | | |
| 5 | Mr. Sok Sothun | 012 434 979 | 5 | | |
| 6 | Ms. Prum Phaldyn | 012 456 535 | 5 | | |
| 7 | Mr. Ban Sambath | 012 790 908 | 5 | | |
| 8 | Mr. Khiev Dara | 016 895 933 | 5 | | |
| 9 | Mr. Nget Sopheap | 012 441 104 | 5 | | |
| 10 | Ms. Kao Sokdet | 012 533 135 | 5 | | |
| 11 | Miss Om Mommary | 012 527 778 | | 10000 | |
| 12 | Mr. Em Poul | 012 917 398 | | 10000 | |

| | | | | | |
|---|---|---|---|---|---|
| 13 | Mr. Nuon Heap | 012 851 587 | | 10000 | |
| 14 | Mr. Mao Vannak | 016 712 434 | | 10000 | |
| 15 | Mr. Seng Sophal | 012 520 780 | | 10000 | |
| 16 | Mr. Bo Dine | | | 5000 | |
| 17 | Ms. Ravin | 012 973 810 | | 1000 | |
| 18 | Miss Hing Phearanich | 012 800 107 | 5 | | 4 Books + 10 Pencils |
| 19 | Miss Sam Eng | 012 617 225 | 5 | | 4 Books + 10 Pencils |
| 20 | Ms. Kan Sotheavy | | 5 | | |
| 21 | Mr. Kim Lim Eang | 012 976 272 | 3 | | |
| 22 | Miss Say Voleak | | 5 | | |
| 23 | Miss Tini Tevika | | 5 | | |
| 24 | Miss Suong Chanlina | 012 531 382 | 5 | | |
| 25 | Miss Duong Socheata | 012 265 321 | 5 | | |
| 26 | Mr. Yoib Meta | 012 875 701 | 10 | | |
| 27 | Mr. Neb Sinthay | 012 527 004 | 10 | | |
| 28 | Mr. Lam Socheat | 012 718 611 | 5 | | |
| 29 | Miss Khim Nina | 012 684 582 | 5 | | |
| 30 | Miss Soung Kaclika | 012 674 895 | 2 | | |
| 31 | Mr. Dara Rith | | | 5000 | |
| 32 | Mr. Nop Meanith | 012 444 167 | | 15000 | |
| 33 | Mr. Meas Kimsan | 016 863 849 | 10 | | |
| 34 | Mr. Heng Rithea | (USA) | 10 | | |
| 35 | Mr. Heng Sophanna | 017 796 066 | 5 | | |
| 36 | Ms. Meas Chanthavy | 016 936 355 | 10 | | |
| 37 | Ms. By Dilen | 012 596 412 | 5 | | |
| 38 | Mr. Pok Leaksmy | 012 870 051 | 10 | | 17 Reading Books |
| 39 | Ms. Kak Vireak Theary | | | | 4 Books + 10 Pencils |
| 40 | Mr. Buth Rithy | 092 999 478 | | 10000 | |
| **Total** | | | **230** | **86000** | **29 Reading Books and 30 Pencils** |